**សុន្ទរកថារបស់ លោក ជីចា តាយហ្សូ**
**លេខាទីពីរ ស្ថានទូតជប៉ុន**
**ថ្លែងក្នុងពិធីសម្ពោធដាក់អោយប្រើប្រាស់ផ្លូវបេតុងអាមេ នៅភូមិផ្សារព្រំ**
**សម្រាប់កែលម្អប្រព័ន្ធលូ ក្នុងស្រុកសាលាក្រៅ ខេត្តប៉ៃលិន**
ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៥

- **សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ**
- **សូមគោរព ឯកឧត្តម កើត សុធា ប្រធានក្រុមប្រឹក្សាខេត្តប៉ៃលិន**
- **សូមគោរព លោក អ៊ាត សារ៉ាត់ អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តប៉ៃលិន**
- **សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងណាស់ ដែលបានមកចូលរួមក្នុងពិធីសម្ពោធផ្លូវបេតុងអាមេមួយខ្សែនៅភូមិផ្សារព្រំ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន ជាមួយវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម កើត សុធា** ប្រធានក្រុមប្រឹក្សាខេត្តប៉ៃលិន។ ជាបឋម ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តប៉ៃលិន និងប្រជាជនដែលរស់នៅក្នុងតំបន់នេះ ដែលបានរៀបចំឲ្យមានកម្មវិធីនេះឡើង។

ការកែលម្អប្រព័ន្ធលូ គឺជាវិស័យអាទិភាពមួយនៃកិច្ចសហប្រតិបត្តិការរបស់ជប៉ុនសម្រាប់កម្ពុជា ហើយជាក់ស្តែងគម្រោងកែលម្អប្រព័ន្ធលូជាច្រើន ត្រូវបានអនុវត្តទាំងនៅទីក្រុង និងតំបន់ជនបទ។ ហើយឥឡូវនេះ គម្រោងកែលម្អផ្លូវបេតុងអាមេ មួយខ្សែប្រវែង ៥០០ម៉ែត្រ នៅស្រុកសាលាក្រៅ ត្រូវបានសាងសង់រួចរាល់ជាស្ថាពរនៅក្នុងខេត្តប៉ៃលិន។

ខ្ញុំយល់ដឹងច្បាស់ណាស់ថា ការសាងសង់ផ្លូវបេតុងនៅក្នុងស្រុកសាលាក្រៅនេះ អាចផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណ៥,៦០០នាក់ដែលរស់នៅក្នុងតំបន់នេះ ដោយផ្តល់ភាពងាយស្រួលក្នុងការធ្វើដំណើរទៅកាន់មន្ទីរពេទ្យ សាលារៀន និងផ្សារជាដើម។ គម្រោងនេះត្រូវបានរំពឹងថា នឹងរួមចំណែកក្នុងការលើកស្ទួយសេដ្ឋកិច្ចក្នុងតំបន់ផងដែរ។

ខ្ញុំសង្ឃឹមថាមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តប៉ៃលិន នឹងថែទាំផ្លូវនេះឲ្យបានល្អ ដើម្បីអោយប្រជាពលរដ្ឋក្នុងតំបន់នេះ អាចទទួលបានអត្ថប្រយោជន៍យូរអង្វែង។

ជាចុងក្រោយនេះ ខ្ញុំសូមសំដែងនូវការកោតសរសើរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកធ្វើឲ្យការអនុវត្តគម្រោងនេះប្រព្រឹត្តទៅបានយ៉ាងរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាផ្លូវនេះ នឹងក្លាយជានិមិត្តរូបនៃមិត្តភាពរវាងប្រទេសយើងទាំងពីរ ព្រមទាំងជួយពង្រឹងជាបន្តនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណ!**